# ទំនុកដំកើង ១២៥

អ្នកនិពន្ធ រុហ្វ លេភិឡារ

ទំនុកដំកើងនេះពិពណ៌នាអំពី

១. សហគមន៍មួយដែលជឿលើព្រះជាម្ចាស់ ដែលពួកគេទុកចិត្តលើព្រះយេហូវ៉ាហើយស្វែងរកសន្តិភាពរបស់ពួកគេនៅក្នុងទ្រង់ (ខ. ១, ២)។

២. សហគមន៍មួយដែលត្រូវបានគំរៀមកំហែង ដែលកំពុងរង់ចាំយ៉ាងអត់ធ្មត់រហូតដល់ព្រះយេហូវ៉ាដកយកបន្ទុករបស់ដំបងនៃសេចក្តីអាក្រក់ចេញ (ខ. ៣)។

៣. សហគមន៍មួយដែលមានមនុស្សល្អនិងមនុស្សអាក្រក់រស់នៅចូលគ្នា (ខ. ៤-៥)។

**ខ. ១** នេះគឺជាទំនុកដំកើងទីបីនៅក្នុងក្រុមទីពីរដែលមានទំនុកដំកើងបី (សូមមើលការនែនាំសំរាប់ទំនុកដំកើង ១២០-១៣៤) ដែលម្តងទៀតយើងមកដល់យេរូសាឡឹម។ ស៊ីយ៉ូនគឺជានិមិត្តសញ្ញាឬពាក្យប្រៀបសំរាប់ទីក្រុង យេរូសាឡឹមនៅសម័យនោះ។ ប៉ុន្តែពាក្យប្រៀបនេះរួមបញ្ចូលផ្នែរឿងដែលទាក់ទងមួយចំនួន។ នៅក្នុងផ្នែកខុសៗគ្នានៃបទគម្ពីរយើងមើលឃើញគំនិតដែលទាក់ទងនឹងស៊ីយ៉ូនដូចតទៅនេះ:

១. ព្រះវិហារជាទីគង់នៅរបស់ព្រះយេហូវ៉ា

២. ប្រជារាស្ត្រសម្ព័ន្ធមេត្រីរបស់ព្រះ ទាំងអ៊ីស្រាអែលដែលបោះបង់ចោលសេចក្តីជំនឿនិងទទួលការវិនិច្ឆ័យ ហើយនិងពួកសំណល់ដែលបានញែកជាបរិសុទ្ធដែលទទួលព្រះពររបស់ព្រះ។

៣. នគររបស់ស្តេចដាវីឌដែលនាំទៅដល់ព្រះមែស្ស៊ី

៤. ចំនុចកណ្តាលនៃពិភពលោកដែលច្បាប់របស់ព្រះត្រូវបានដាក់ចេញទៅ ហើយពួកសាសន៍ដទៃក្នុងពិភពលោកនឹងមកឯស៊ីយ៉ូន។

៥. ផ្ទៃមេឃនិងផែនដីថ្មីដែលសន្តិភាពនិងភាពចម្រុងចម្រើននឹងសោយរាជ្យ។

ទាំងនៅក្នុងព្រះគម្ពីរសញ្ញាចាស់និងថ្មី ទីក្រុងស៊ីយ៉ូនតំណាងឲ្យប្រជារាស្ត្ររបស់ព្រះ។ នៅក្នុងវិវរណៈ ២១:៩ ទីក្រុងបរិសុទ្ធជាកូនក្រមុំ ជាភរិយារបស់កូនចៀម។ ដូច្នេះក្នុងខ.១ នេះ ប្រជារាស្ត្ររបស់ព្រះ (អស់អ្នកដែលទុកចិត្តដល់ទ្រង់) គឺដូចជាភ្នំស៊ីយ៉ូនដែរ។ អ្នកនិពន្ធមានទំនុកចិត្តថា ប្រជារាស្ត្ររបស់ព្រះហើយនិងភ្នំស៊ីយ៉ូននឹងជាប់នៅជាដរាប ហើយនៅក្នុងកណ្ឌវិវរណៈយើងឃើញថាទីក្រុងបរិសុទ្ធដែលជាប្រជារាស្ត្ររបស់ព្រះពិតជាមាននៅជាដរាប។

**ខ. ២** ខនេះមានការប្រៀបធៀបមួយផ្សេងទៀត។ ដូចដែលភ្នំផ្សេងៗព័ទ្ធជុំវិញ (ហើយការពារ) *យេរូសាឡឹម* នោះព្រះយេហូវ៉ាក៏គង់នៅជុំវិញ*ប្រជារាស្ត្ររបស់ទ្រង់*ផងដែរ។ សូមកត់សំគាល់ម្តងទៀតអំពីទំនាក់ទំនងរបស់យេរូសាឡឹមនិងប្រជារាស្ត្ររបស់ព្រះ។ សូមកត់សំគាល់ម្តងទៀតអំពីការនិយាយដដែលៗនៃឃ្លា «ជាប់នៅជាដរាប»។ អស់អ្នកដែលទុកចិត្តដល់ព្រះអម្ចាស់គឺដូចជាស៊ីយ៉ូនដែលជាប់នៅជាដរាប (ខ. ១) ដោយសារតែព្រះដែលពួកជឿទុកចិត្តនឹងគង់នៅជុំវិញពួកគេជាដរាប (ខ. ២)។

**ខ. ៣** ពាក្យនៃសេចក្តីជំនឿនៅក្នុងខ. ១-២ មិនមែនមកពីអ្នកនិពន្ធស្ថិតនៅក្នុងស្ថានភាពមួយដែលល្អនិងស្រួលមួយដែលនាំគាត់អាចមើលឃើញការគ្រប់គ្រងរបស់ព្រះបានច្បាស់នោះទេ។ ផ្ទុយទៅវិញ គាត់ស្ថិតនៅក្នុងស្ថានភាពអាក្រក់មួយដែលមនុស្សអាក្រក់គ្រប់គ្រង ហើយមនុស្សសុចរិតត្រូវល្បួងឲ្យធ្វើការអាក្រក់។ នេះប្រហែលឬមិនប្រហែលជាមានន័យថា ពួកសាសន៍ដទៃកំពុងបានគ្រប់គ្រង វាអាចសំដៅលើពួកអ្នកដឹកនាំអ៊ីស្រាអែលដែលអាក្រក់។ ក្នុងខ. ៥ ពន្យល់អំពីហេតុផលដែលអ្នកនិពន្ធជឿថាការគ្រងរាជ្យរបស់មនុស្សអាក្រក់នឹងមកដល់ទីបញ្ចប់ គឺពីព្រោះព្រះនឹងនាំវាមកដល់ទីបញ្ចប់ដោយអធិបតីភាពរបស់ទ្រង់។

**ខ. ៤** ការធានាថាព្រះនឹងធ្វើការនេះនាំចូលទៅក្នុងសេចក្ដីអធិស្ឋានមួយ។ សូមកត់សំគាល់ថា អ្នកនិពន្ធមិនសំរេចចិត្តថាដោយព្រោះព្រះនឹងធ្វើការនេះដោយអធិបតីភាពរបស់ទ្រង់ នោះគាត់មិនចាំបាច់អធិស្ឋាននោះទេ។ យើងនៅតែអធិស្ឋានសំរាប់ការផ្សេងៗដែលយើងដឹងប្រាកដថានឹងកើតឡើង។ ទាក់ទងនឹងសេចក្ដីអធិស្ឋាននេះយើងដឹងថាអាណាចក្ររបស់ព្រះនឹងមកដល់ជាពិតប្រាកដ ប៉ុន្តែព្រះយេស៊ូវនៅតែបង្រៀនយើងឲ្យអធិស្ឋានថា «សូមឲ្យរាជ្យទ្រង់បានមកដល់»។

**ខ. ៥** ទំនុកដំកើងនេះបញ្ចប់ដោយ «សូមឲ្យសេចក្ដីសុខគ្របលើសាសន៍អ៊ីស្រាអែលផង»។ ផ្លូវមួយដែលយើងអាចមានសន្តិភាពគឺមិនមែនដោយការសម្រុះសម្រួលរវាងមនុស្សល្អនិងមនុស្សអាក្រក់នោះទេ ប៉ុន្តែដោយសារព្រះយេហូវ៉ាបណ្ដេញពួកអ្នកប្រព្រឹត្តការអាក្រក់ចេញហើយបញ្ចប់ការគ្រប់គ្រងរបស់មនុស្សទុច្ចរឹតវិញ។

**ការអនុវត្ត**

ទំនុកដំកើងនេះបញ្ជាក់អំពីអ្វីដែលជារឿយៗត្រូវបានក្រឹត្យវិន័យ ទំនុកដំកើង និងពួកហោរាបានប្រកាស (ចូរថ្លែងប្រាប់ថា មនុស្សសុច្ចរឹតនឹងបានសេចក្ដីសុខវិញ ត្បិតគេនឹងទទួលផលនៃការដែលគេប្រព្រឹត្ត វេទនាដល់មនុស្សអាក្រក់ គេនឹងត្រូវសេចក្ដីទុក្ខព្រួយ ត្បិតការដែលដៃគេបានធ្វើនោះនឹងបានសងដល់គេវិញ អេសាយ ៣:១០-១១)។ ព្រះគម្ពីរសញ្ញាថ្មីបន្តប្រកាសអំពីផ្ទៃរឿងនេះ ហើយបញ្ចប់ដោយផ្ទៃរឿងនេះនៅពេលកំពុងពណ៌នាអំពីផ្ទៃមេឃថ្មីនិងផែនដីថ្មី។ មានតែអស់អ្នកដែលជារបស់ព្រះគ្រីស្ទប៉ុណ្ណោះដែលអាចចូលហើយរស់នៅអស់កល្បជានិច្ចបាន (ទំនុកដំកើង ២២:១៤ ប្រៀបធៀបៈ ទំនុកដំកើង ១២៥:១-២) តែមនុស្សទុច្ចរឹតនឹងមិនអាចចូលបានទេ ហើយនឹងត្រូវបានបណ្ដេញចេញទៅឯបឹងភ្លើងវិញ (វិវរណៈ ២១:៨-១០, ២៧, ២២:១៥)។ ការនេះគួរលើកទឹកចិត្តយើងឲ្យបន្តទុកចិត្តដល់ព្រះគ្រីស្ទហើយមិនត្រូវងាកបែរទៅរកការអាក្រក់នោះឡើយ។

**Bibliography**


Carson, D.A., R. T. France, J. A. Motyer & G. J. Wenham, Ed. (1994), *New Bible commentary: 21st century edition*, (4th ed.) Leicester, England; Downers Grove, IL: Inter-Varsity Press.

Henry, M. (1994), *Matthew Henry's commentary on the whole Bible: Complete and unabridged in one volume*, Peabody: Hendrickson.

Kidner, D. (1975). *Vol. 16*: *Psalms 73–150: An Introduction and Commentary*. Tyndale Old Testament Commentaries. Nottingham, England: Inter-Varsity Press.

Ryken, L., Wilhoit, J., Longman, T., Duriez, C., Penney, D., & Reid, D. G. (2000). *Dictionary of Biblical Imagery*. Downers Grove, IL: InterVarsity Press.

Wilcock, Michael. (2001), *The Message of Psalms 73-150.* The Bible Speaks Today Commentaries. Leicester, England: Inter-Varsity Press.


www.dkdl.org